**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
ROYAUME DU CAMBODGE
Nation Religion Roi

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTERE DE L'ECONOMIE ET DES FINANCES

លេខ: ៥៧៥ សហវ.ប្រក.

រាជធានី ភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ ០១ នស/រកម/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃ ទី ២២ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពី ប្រព័ន្ធគណនីរបស់រតនាគារជាតិ ។
- តាមការចាំបាច់របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ១:** ត្រូវបានបំពេញបន្ថែមនៅក្នុងប្រពន្ធ័គណនីនៃគណនេយ្យរដ្ឋ នូវគណនីដែលមានឈ្មោះ និង លេខសំគាល់ដូចខាងក្រោម ៖

**ក- គណនីសំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់ធនាគារពិភពលោក (WB) ដែលមានគណនី**

**លេខ 543**

គណនីនេះត្រូវបំបែកទៅជាអនុគណនីមួយចំនួន ដើម្បីឆ្លុះបញ្ចាំងទៅតាមគំរោងការនានារបស់ធនាគារពិភពលោក ៖

១- អនុគណនីលេខ **543.01** សំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់ធនាគារពិភពលោក រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយឆ្លុះបញ្ចាំងទៅនឹងគណនីលេខ **0100-39-1211-T064** ជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា ។

២-អនុគណនីលេខ **543.02** សំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់ធនាគារពិភពលោករវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយអគ្គីសនីកម្ពុជា ហើយឆ្លុះបញ្ចាំងទៅនឹងគណនីលេខ **0102-35-1211-T080** ជាប្រាក់ដុល្លាអាមេរិក នៅធនាគារជាតិនៃកម្ពុជា ។

**ខ-គណនីសំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) ដែលមាន**

**គណនីលេខ 544**

គណនីនេះត្រូវបំបែកទៅជាអនុគណនីមួយចំនួន ដើម្បីឆ្លុះបញ្ចាំងទៅតាមគំរោងការនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ៖

- អនុគណនីលេខ **544.01** សំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញហើយឆ្លុះបញ្ចាំងទៅនឹងគណនីលេខ **0100-39-1211-T065** ជាប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា ។

**គ-គណនីសំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់មូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលមានគណនីលេខ 549**

គណនីនេះត្រូវបំបែកទៅជាអនុគណនីមួយចំនួន ដើម្បីឆ្លុះបញ្ចាំងទៅតាមគំរោងការនានារបស់មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម ៖

- អនុគណនីលេខ 549.01 សំរាប់គ្រប់គ្រងប្រាក់កំចីបន្តរបស់មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយធនាគារអភិវឌ្ឍន៍ជនបទ ហើយឆ្លុះបញ្ចាំងទៅនឹងគណនីលេខ 0102-35-1211-T134 ជាប្រាក់ដុល្លាអាមេរិកនៅធនាគារជាតិនៃកម្ពុជា ។

**ឃ-គណនីសំរាប់គ្រប់គ្រងជំនួយជប៉ុន 6 ដែលមានគណនីលេខ 547.06**

គណនីលេខ 547.06 ប្រើសំរាប់កត់ត្រាប្រាក់ជំនួយជប៉ុនទី 6 ជារៀលហើយឆ្លុះបញ្ចាំងទៅនឹងគណនីលេខ 0100-39-1211-T113 នៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ២៖ ប្រព្រឹត្តិកម្មនៃគណនី**

- ខ្ទីមសារនៃគណនីលេខ 543 , 544 , 549 ត្រូវបានកត់ត្រា៖

**ឥណពន្ធ ៖** កត់ត្រាចំនួនទឹកប្រាក់ចំណូលពីការប្រាក់អោយខ្ចីបន្ត ។ ចំនួនទឹកប្រាក់នេះត្រូវបានកត់ត្រាបដិភាគជាមួយគណនីចំណូលថវិការដ្ឋ ។

**ឥណទាន៖** កត់ត្រាចំនួនទឹកប្រាក់បានផ្ទេរចេញដោយបង្វែរទៅគណនីផ្សេងទៀត (ជាប្រតិបត្តិការរតនៈវត្ថុ) ឬ ទូទាត់ចំណាយថវិកា ( ប្រតិបត្តិការថវិកា ) ។

**សមតុល្យឥណាយិក៖** ឆ្លុះបញ្ចាំងចំនួនទឹកប្រាក់កំពុងមាន នៅធនាគារជាតិនៃកម្ពុជា ។

- ខ្ទីមសារនៃគណនីលេខ 547.06 ត្រូវបានកត់ត្រា ៖

គណនីលេខ 547.06 ត្រូវបានកត់ត្រានៅរតនាគារជាតិដូចគណនីជំនួយជប៉ុនដទៃទៀត ។

**ប្រការ៣៖** គណនីលេខ 543, 544, 549 រតនាគារជាតិអាចបំបែកទៅជាអនុគណនីបន្ថែមទៀតក្រៅពីអនុគណនីទាំងឡាយ ដែលបានកំណត់ខាងលើទៅតាមតំរូវការជាក់ស្តែងដែលទាក់ទងនឹងប្រភេទ-ចារីកនៃប្រតិបត្តិការថ្មីៗទៀត ។

**ប្រការ៤:** កិច្ចបញ្ជីការនៅរតនាគារជាតិត្រូវផ្អែកទៅតាមសក្ខីបត្រដើម ដែលធនាគារជាតិនៃកម្ពុជា នាយកដ្ឋានពាក់ពន្ធ័ និង អង្គភាពគ្រប់គ្រងរូបិយបណ្ណផ្ញើមកតាមកិច្ចប្រតិបត្តិការនិមួយៗ ។ នៅរៀងរាល់ដំណាច់ខែ រតនាគារជាតិត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយធនាគារជាតិនៃកម្ពុជា និង អង្គភាពពាក់ពន្ធ័នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៥:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាន រតនាគារជាតិ និង អង្គភាពពាក់ពន្ធ័ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះ ហត្ថលេខាតទៅ ៕/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣:
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ